# “ការងារបូកស៊ីម៉ងត៍និងបៀកស្រទាប់ខាងក្នុង”

## ចំណុចសំខាន់សម្រាប់សុវត្ថិភាពនិងសុខភាព

# ជណ្ដើរ, តុការងារចល័ត

## ( 1 ) ចូរប្រាកដថាបានត្រួតពិនិត្យមុននឹងប្រើប្រាស់! ( តុការងារចល័ត )




## បញ្ហាដែលត្រូវអនុវត្ត

1. ពិនិត្យមើលឧបករណ៍បង្ការការធ្លាក់ចូលប្រឡោះ, កៅស៊ូទប់រអិលជើងជណ្ដើរ និងដែកកែងកំណត់បង្រួម និងហាមប្រើដែកកែងដែលខូច ។
2. គួរតែដំឡើងជណ្ដើរនៅត្រង់ទីកន្លែងរាបស្មើនិងមានលំនឹង ។

## (2) សុវត្ថិភាពក្នុងការឡើងនិងចុះពីតុការងារចល័ត



### បញ្ហាដែលត្រូវអនុវត្ត

1. ហាមឡើងនិងចុះដោយខ្នងបែរទៅរកតុការងារ។
2. ឡើងនិងចុះដោយដៃកាន់បង្គោលតោង ឬគ្រោងមេ។
3. ហាមឡើងនិងចុះដោយដៃកាន់វត្ថុ។

## (3) ហាមបំពេញការងារក្នុងជំហរមិនសមស្រប!



**បញ្ហាដែលត្រូវអនុវត្ត**

1. ហាមបំពេញការងារនៅក្នុងជំហរមិនសមស្រប។
2. ហាមអើតផុតពីលើផ្ទៃតម្រឹម។
3. ហាមដាក់វត្ថុនៅជុំវិញតុការងារ។

## (4) ហាមដាក់ជណ្ដើរឬកៅអីនៅលើតុការងារ



### បញ្ហាដែលត្រូវអនុវត្ត

1. ហាមដាក់ជណ្ដើរឬកៅអីនៅលើតុការងារ។
2. ចូរដំឡើងតុការងារក្នុងកម្ពស់សមស្រប។

## (5) នៅពេលដំឡើងតុការងារ ចូរពិនិត្យមើលជើង!




### បញ្ហាដែលត្រូវអនុវត្ត

1. នៅពេលដំឡើង ចូរដំឡើងវានៅកន្លែងដែលមិនមានរន្ធនៅត្រង់ជើង។
2. ដំឡើងនៅត្រង់កន្លែងដែលស្អាតនិងមានសណ្ដាប់ធ្នាប់។
3. ចៀសវាងតំបន់ដែលគ្មានសំណាញ់បាំងបញ្ឈរឬផ្ដេកនៅជុំវិញប្រឡោះ ដែលគ្មានអ្វីយាំង។

## (6) ហាមមនុស្សពីរនាក់ស្ថិតនៅលើផ្ទៃតហ្វមក្នុងពេលតែមួយ



### បញ្ហាដែលត្រូវអនុវត្ត

1. មិនគួរឲ្យមនុស្សពីរឬបីនាក់ធ្វើការងារនៅលើតុក្នុងពេលតែមួយឡើយ។
2. ហាមផ្លាស់ទីពីផ្ទៃតហ្វមមួយទៅផ្ទៃតហ្វមមួយទៀត។
3. ប្រសិនបអ្នកចាំបាច់ត្រូវធ្វើការនៅលើផ្ទៃតហ្វមផ្សេងៗ អ្នកត្រូវតែចុះសិនទើបឡើងលើផ្ទៃតហ្វមមួយទៀត។

# (7) ចូរប្រាកដថាបានត្រួតពិនិត្យមុននឹងប្រើប្រាស់! [ជណ្ដើរ]

ចូរពិនិត្យមើលផ្នែកនីមួយៗ
- វីស, កន្លាស់សឹកធូរ, ធ្លាក់
- ការរបូតផ្នែកផ្សេងៗ
- ទល់, កាំជណ្ដើរ, ការខូចទ្រង់ទ្រាយគ្រឿងជណ្ដើរ, ការខូចខាត




## បញ្ហាដែលត្រូវអនុវត្ត

1. ពិនិត្យមើលប្រដាប់ខ្ទាស់, កៅស៊ូទប់រំអិលជើងជណ្ដើរ និងដែកកែងកំណត់ពន្លូត និងហាមប្រើដែកកែងដែលខូច។
2. គួរតែដំឡើងជណ្ដើរនៅត្រង់ទីកន្លែងរាបស្មើនិងមានលំនឹង។

# (8) ហាមបែរខ្នងបំពេញការងារទល់នឹងកាំជណ្ដើរ!



## បញ្ហាដែលត្រូវអនុវត្ត

1. ហាមបែរខ្នងបំពេញការងារទល់ជណ្ដើរ។
2. ហាមបំពេញការងារដោយឈរនៅលើបន្ទះខាងលើ។